# តួនាទីមនុស្ស



ផាតកាភិវង្ស

# តួនាទីមនុស្ស

ដោយ ៖ ជាគរាភិវង្ស

**ក្នុងជីវិតមនុស្សគ្រប់ស្រទាប់វណ្ណៈ យើងត្រូវយល់ពីៈ**

*១) **នាទីរបស់ខ្លួន ដែលត្រូវធ្វើឲ្យខ្លួនឯង** បានដល់ ការយល់ហេតុយល់ផល សិក្សាស្វែងរកប្រយោជន៍សុខ ដែលប្រាសចាកទោសមកឲ្យខ្លួនឯង នេះគឺជាតួនាទីដែលយើងត្រូវធ្វើ គឺរាប់តាំងតែតួនាទីថ្នាក់តូចថ្នាក់ទាប ទៅរហូតដល់ថ្នាក់ខ្ពស់ ដែលយើងត្រូវធ្វើឲ្យខ្លួនឯង ជាពិសេសនៅក្នុងស្រទាប់យុវវ័យ ឬវ័យកណ្តាលរហូតឈានទៅដល់បច្ឆិមវ័យ នៅក្នុងរវាងវ័យទាំងនេះ យើងត្រូវរៀបចំជីវិតយើងយ៉ាងណាខ្លះ ដើម្បីឲ្យទទួលបាននូវសេចក្តីសុខ ? នាទីរបស់ខ្លួនក្នុងមួយថ្ងៃៗ ត្រូវអនុវត្តនូវគោលការណ៍អ្វីខ្លះ ត្រូវប្រកប ត្រូវគិត ត្រូវច្នៃប្រឌិតយ៉ាងណាខ្លះ ? ឬគ្រាន់តែរស់នៅឲ្យថ្ងៃយប់កន្លងហួសទៅដើម្បីដកដង្ហើមចេញចូលប៉ុណ្ណឹងទេ ? ឬគ្រាន់តែដើម្បីស្វែងរកការសប្បាយភ្លើតភ្លើនដែលបានពីការសេពសោយ ទទួលបាននូវរបស់ដែលខ្លួនចង់បានមួយថ្ងៃៗ ប៉ុណ្ណឹងទេ ? យើងត្រូវចងចាំទុកថា "ការសម្រេចចិត្តធ្វើអ្វីមួយក៏ដោយ ផលដែលកើតប្រាកដមក ហ្នឹងគឺជាជតាកម្ម គឺជាព្រហ្មលិខិត នៃជីវិតរបស់មនុស្សម្នាក់ៗ ដែលត្រូវតែទទួល" "ខ្លួនយើងហ្នឹង គឺជាអ្នកកំណត់ជតាកម្មជីវិតឲ្យខ្លួនយើង ទាំងក្នុងបច្ចុប្បន្នេះ និងទៅអនាគតខាងមុខ" "យើងធ្វើល្អ យើងបរិសុទ្ធ យើងធ្វើអាក្រក់ យើងសៅហ្មង រឿងល្អរឿងអាក្រក់ទាំងអស់ហ្នឹង វាជាធម្មជាតដែលបានមកពីកាយព្រឹត្តកម្ម វចីព្រឹត្តកម្ម និងមនោព្រឹត្តកម្ម នៃយើងផ្ទាល់ម្នាក់ៗ ហ្នឹងឯង"*

**នាទីរបស់ខ្លួន ដែលត្រូវធ្វើឲ្យខ្លួនឯងនេះ ហៅថា៖**

**១.១)** អត្តត្ថចរិយា ប្រែថា ការប្រព្រឹត្តប្រយោជន៍ឲ្យខ្លួនឯង ក៏បាន

១.២) ការធ្វើនាទីរបស់ខ្លួនឲ្យបរិបូរណ៍ ក៏បាន

បុគ្គល ៤ ពួកក្នុងសង្គមមនុស្សគឺ៖

១) **ពួកសាងប្រយោជន៍សុខឲ្យតែខ្លួនឯង មិនសាងប្រយោជន៍សុខឲ្យ ដល់អ្នកដទៃ** បានដល់

ក) ពួកកំណាញ់ស្វិត គិតតែពីបាន មិនមានបង់ ( ខាងផ្នែកទ្រព្យសម្បត្តិ )

ខ) ពួកភ្លូវស្រែលើខ្នងអ្នកក្រ

គ) ពួកហុតទឹកសម្លីងកាក

ឃ) ពួកវ៉ៃអែបស៊ីអប

ង) ពួកសេះមាត់ពីរ ឬពួកធ្មិនក្បាលស៊ីក្បាល ធ្មិនកន្ទុយ ស៊ីកន្ទុយ

ពិតណាស់ហើយដែលថា ក្រពះពោះវៀនមនុស្សយើងម្នាក់ៗ ត្រូវការអាហារបាយទឹក បើមិនឲ្យស៊ី មានតែងាប់ ហើយការដែលត្រូវបានស៊ី វាទាល់តែស៊ីឲ្យខ្លួនឯងឆ្អែតជាមុនសិន ទើបបែងរំលែកឲ្យអ្នកដទៃតាមក្រោយបាន តែអ្វីដែលយើងគួរគិតនោះគឺ ធម្មជាតិមនុស្ស ចិត្តសន្តានមនុស្ស មនុស្សមិនមែនដូចជាសត្វធាតុនោះទេ អ្នកខ្លះចិញ្ចឹមសត្វឆ្កែទុក ពេលឲ្យបាយវាស៊ីម្ដងៗ ត្រូវឲ្យវារង់ចាំទាល់តែខ្លួនបរិភោគឆ្អែតជាមុនសិន ហើយទើបគ្គិះកៀរកម្ទេចកម្ទីដែលសេសសល់ដាក់

ឲ្យគ្នាស៊ី តែមនុស្សវិញមិនមែនដូច្នេះទេ តម្រូវការនៃមនុស្សគ្រប់គ្នា ដែលមានដូចៗ គ្នានោះគឺ ចង់បានសុខ ស្អប់ទុក្ខ តែដែលមនុស្សមិនបានផ្តល់ឲ្យសេចក្តីសុខដល់គ្នានឹងគ្នានោះ ព្រោះតែធមិ ៣ យ៉ាងគ្រប់សង្កត់សន្តានចិត្ត ធ្វើឲ្យជាមនុស្សខ្វាក់ទាំងភ្លឺ មើលមិនឃើញទាំងថ្ងៃបើក គឺ៖

១) **តណ្ហា** សេចក្តីប្រាថ្នាមិនមានកំណត់ រហូតដល់មានហើយ ក៏ដូចជាអត់ខ្សត់ទាំងខ្លួនដេកននៀលលើគំនរមាសប្រាក់ ជាតិជាសាមញ្ញមនុស្ស មិនមានអ្នកម្នាក់ដែលមិនមានសេចក្តីប្រាថ្នាចង់បាននោះទេ តែសេចក្តីប្រថ្នាត្រូវការនោះ៖

១.១) ត្រូវកុំឲ្យបៀតបៀនអ្នកដទៃ

១.២) ត្រូវមានកម្រិតព្រំដែនក្នុងជីវិត ឬត្រូវស្គាល់ប្រមាណ ក្នុងការស្វែងរកបានមក

១.៣) ត្រូវប្រកបដោយសុចរិតកម្ម ឬបានមកដោយទង្វើរល្អបរិសុទ្ធ

**២) ទិដ្ឋិ** ការជឿមាំតែលើខ្លួនឯងម្នាក់ ឬការប្រកាន់មាំថា មានតែខ្លួនឯងដែលគិតត្រូវ ទើបជាហេតុមួយធ្វើឲ្យមនុស្សគិតឃើញតែពីបានសម្រាប់ខ្លួន ព្រោះយល់ឃើញថា មានតែទស្សនៈគំនិតខ្លួនឯងប៉ុណ្ណោះ ប្រសើរត្រឹមត្រូវជាងអ្នកដទៃ ហើយក៏ប្រកាន់មាំ ក្នុងគំនិតខ្លួនឯង មិនព្រមបើកសោតទ្វារទទួលដឹងសំឡេងអ្នកដទៃៗ ទៀត រហូតក្លាយទៅជាកើតបញ្ហាឲ្យដល់សង្គម បៀតបៀនគ្នា មិនយល់សុខទុក្ខនៃគ្នានឹងគ្នាជាដើម ។

៣) **មានះ** ភាពរឹងត្អឹង ឆ្មើងឆ្មៃ វ៉ៃឫក ដោយនឹកថាខ្លួនហ្នឹងឯង គ្រាន់ជាងអ្នកទាំងពួង ពេលយើងដើរតាមផ្សារ ឬថ្នល់សាធារណៈ យើងនឹងឃើញស្រ្តីមួយចំនួនពាក់ស្បែកជើងកែងចោតដើរលាន់សូរតែក្រិបក្រប់ៗ សួរថា ពាក់ដើម្បីអ្វី ? គឺដើម្បីឲ្យវាលូតកម្ពស់ហើយមើលមករំលេចទ្រង់ទ្រាយស្អាត ដល់ក្រសែភ្នែកអ្នកផង តែតាមសភាពពិតមនុស្សកម្ពស់ ១.៥០ ម៉ ក៏បរិមាណដើមនៅតែ ១,៥០ ម៉ ហ្នឹងឯង តែដែលខ្ពស់ទៅដល់ ១,៦០ ម៉ នោះ ព្រោះកែងចោតវាជួយលើក ជួយស្ទួយ យ៉ាងណាមិញ មនុស្សយើងម្នាក់បរិមាណនៃគំនិត គុណភាពនៃសេចក្តីល្អ មិនមានអ្នកណាដូចគ្នា ស្មើគ្នានោះទេ តែអ្វីដែលមនុស្ស យើងចូលចិត្តនោះ គឺលើកកម្ពស់ខ្លួនឯង ចង់ឲ្យខ្លួនឯងប្រសើរ ខ្ពង់ខ្ពស់ ជាងអ្នកដទៃ ទាំងដែលដឹងថា ភាពខ្ពង់ខ្ពស់ ឬកេរ្តិ៍ឈ្មោះដែលត្រូវបានមកនោះ វាមិនស័ក្តិសម មិនមានតុល្យភាពជាមួយខ្លួនក៏ដោយ ក៏នៅតែចង់បាន ព្រោះនេះគឺជាសន្តានមនុស្ស ការវ៉ៃឫកពារខ្ពស់ទាបនេះឯង គឺជាហេតុជាបច្ច័យសាងបញ្ហាឲ្យដល់ខ្លួនយើងផ្ទាល់ផង ដល់សង្គមទាំងមូលផង ។ មនុស្សដែលច្រើនទៅដោយភាពរឹងត្អឹងវ៉ៃឫកឆ្មើងឆ្មៃព្រោះ៖

ក) ជាតិត្រកូល ( កើតក្នុងត្រកូលសេដ្ឋីមូលធន )

ខ) ទ្រព្យសម្បត្តិ

គ) ឋានៈយសស័ក្តិ

ឃ) ការសិក្សា

ង) រូបសម្បត្តិ ( មានរូបរាងសណ្ឋានទ្រង់ទ្រាយ ល្អសមសួន )

ច) បរិវារសម្បត្តិ ( មានបក្សពួកខ្សែស្រឡាយអ្នកធំអ្នកតូចច្រើន ) ជាដើម

២) ***ពួកសាងប្រយោជន៍សុខឲ្យដល់អ្នកដទៃ តែមិនសាងប្រយោជន៍សុខឲ្យខ្លួនឯង*** បានដល់

ក) អ្នកជួយប្រាប់ ជួយពន្យល់ ជួយណែនាំអ្នកដទៃ តែមិនជួយខ្លួនឯង បុគ្គលប្រភេទនេះទុកដូចជាស្ពាន ដែលគ្រាន់តែសម្រាប់ចម្លងអ្នកដទៃ ឬទុកដូចវែកក្នុងឆ្នាំងសម្លដែលគ្រាន់តែសម្រាប់ដួសគ្រឿង និងកូរសម្ល តែមិនបានស្គាល់រសជាតិសម្លឡើយ

ខ) អ្នកលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីសាងសេចក្តីសុខ ឲ្យដល់មនុស្សក្នុងសង្គម គឺអ្នកមានឧត្តមគតិខ្ពស់ យកសេចក្តីទុក្ខរបស់មនុស្សសត្វក្នុងលោកមកជាជំហានទីមួយក្នុងការដោះស្រាយដំណើរជីវិតរាល់ព្រឹត្តកម្ម ដែលមនុស្សប្រភេទនេះធ្វើទៅសុទ្ធសឹងតែមានសុខទុក្ខរបស់សព្វសត្វមកជាអារម្មណ៍ បុគ្គលប្រភេទនេះ បានដល់

ក) ព្រះសម្មាសម្ពុទ្ធជាម្ចាស់

ខ) អ្នកដឹកនាំប្រទេស អង្គការ ស្ថាប័ន ដែលប្រកបដោយគតិធម៌ យុត្តិធម៌

គ) បណ្ឌិតអ្នកប្រាជ្ញ ដែលឧទ្ទិសខ្លួនដើម្បីជាតិ សាសនា

៣) ***ពួកដែលសាងប្រយោជន៍សុខឲ្យដល់ខ្លួនឯងផង ដល់អ្នកដទៃផង*** បានដល់ អ្នកដែលមានទាន សីល ប្រព្រឹត្តសេចក្តីល្អទូទៅ អ្នករស់នៅក្នុងសង្គម និងបានជួយសង្គម បុគ្គលប្រភេទនេះ ឈ្មោះថា

១) រស់នៅមិនចង្អៀត មិនធូន់ ផែនដី

២) កើតមកបានសាងប្រយោជន៍ ស្លាប់ទៅបានទុកកេរ្តិ៍ឈ្មោះ

៣) មកទាំងគេទទួលស្វាគមន៍ ទៅទាំងឲ្យគេអាល័យ

៤) **ពួកដែលមិនសាងប្រយោជន៍សុខឲ្យដល់ខ្លួនឯង និងមិនសាង ប្រយោជន៍សុខឲ្យដល់អ្នកដទៃ** បានដល់

១) ចង្អៀតផែនដី

២) សាងភារៈបញ្ហាឲ្យដល់សង្គម

៣) ទុកដូចជាឈើងសង្គម ឬបញ្ញើក្អែកក្នុងសង្គម

២) **នាទីរបស់ខ្លួន ដែលត្រូវធ្វើឲ្យពពួកញាតិវង្សានុវង្ស** បានដល់ ការបំពេញប្រយោជន៍សុខឲ្យដល់ញាតិវង្សានុវង្សក្នុងត្រកូល ដោយការជួយសង្គ្រោះ ជ្រោមជ្រែងក្នុងផ្នែកនៃសេចក្ដីល្អដែលអាចធ្វើទៅបាន និងដែលត្រូវតែតាំងចិត្តធ្វើ គឺ៖

២.១) មានការឲ្យទានចែករំលែកជួយឃឹតយោង សន្ដោងវង្សត្រកូល

២.២) មានពាក្យសម្ដីពីរោះពិសា ទន់ភ្លន់ហើយប្រកបដោយប្រយោជន៍ ឬហៅថា៖

ក) សម្ដីទឹកឃ្មុំ ព្រោះជាពាក្យផ្អែមល្ហែម

២) សម្តីផ្កា ព្រោះជាពាក្យមានប្រយោជន៍ក្រអូបឈ្ងុយឈ្ងប់ ដោយជៀសវាង ការពោលពាក្យដែលធ្វើឲ្យបែកបាក់ដល់សន្តមញ្ញាតិរបស់ខ្លួន ឬគ្រួសាររបស់ខ្លួន គឺ៖

ក) ពាក្យផ្តាសាជេរប្រទេច ទ្រគោះបោះបោក ឬហៅថា "សម្តីក្រៀមក្រោះ អត់រសជាតិ សម្តីទឹកស្តៅ សម្តីទឹកអម្បិល សម្តីមុខកំបិត" ក៏បាន

ខ) ពាក្យចាក់រុក ញុះញង់ បំបែកបំបាក់ ពង្រាត់បង្រាស ឬហៅថា "សម្តីផ្តាច់សាមគ្គី សម្តីផ្តាច់សុខ សម្តីមនុស្សច្រណែនសុខ" ក៏បាន

គ) សម្តីអត់មានន័យខ្លឹមសារ រាត់រាយ ប៉ាបាច់ប៉ប៉ោច ឬហៅថា "សម្តីទាត់សី សម្តីទាត់បាល់ សម្តីមនុស្សមនុស្សឆ្កួត សម្តីអត់បាយ" ក៏បាន

សម្តីទាំង ៣ នេះ ក្នុងនាមយើងជាសមាជិកមួយក្នុងគ្រួសារ ក្នុងវង្សត្រកូល យើងត្រូវជៀសវាងនិយាយ ការធ្វើបានយ៉ាងនេះ ឈ្មោះថា បានធ្វើប្រយោជន៍សុខឲ្យដល់ពួកញាតិវង្សរបស់ខ្លួន។ តាមពិតទៅ ធម្មជាតិមនុស្សយើង ហាមឃាត់មិនឲ្យនិយាយ មិនបានជាដាច់ខាត និយាយឲ្យខ្លឹមកគឺ "អត់និយាយ មិនបាន" គឺត្រូវតែនិយាយចរចាឆ្លងឆ្លើយ អស់ពីរឿងមួយទៅរឿងមួយ ដើម្បីកាត់បន្ថយភាពតឹងណែនអួរអាប់ក្នុងចិត្តចេញមកឲ្យអ្នកដទៃ បានទទួលដឹងផង ហើយក៏សប្បាយចិត្ត តែមិនត្រូវភ្លេចថា ទន្ទឹមនឹងបាននិយាយពីរឿងអ្វីមួយក្នុងចិត្តយើងចេញមកនោះ វាបានឆ្លងកាត់ក្រដាសត្រចៀកអ្នកដទៃ ចូលទៅដល់បេះដូងគេផងដែរ ហើយពាក្យរបស់យើងនោះសោត អាចធ្វើឲ្យបេះដូងគេសុខក៏បាន ទុក្ខក៏បាន ដូច្នេះ ត្រូវប្រយ័ត្នពាក្យសម្តី ព្រោះ៖

ក) សម្តី គឺជាអាវុធមុខពីរ ស្រេចហើយតែអ្នកយកទៅប្រើ

ខ) សម្តីល្អ គឺជាថ្នាំស័ក្តិសិទ្ធិមួយសម្រាប់មនុស្សឈឺ

គ) សង្គ្រាមពាក្យសម្តី ឆេះតិច តែផុំយូរ ហើយលំបាកនឹងពន្លត់

ឃ) មនុស្សក្នុងសង្គមសព្វថ្ងៃ រស់ព្រោះសម្តី ស្លុយព្រោះសម្តី ធ្លាក់នរក ព្រោះសម្តី ឡើងស្ថានសួគ៌ ក៏ព្រោះសម្តី ការបំពេញតួនាទីរបស់ខ្លួន ឲ្យដល់ពពួក ញាតិវង្សនេះ ហៅថា៖

១) ញាតត្ថចរិយា ការបំពេញប្រយោជន៍ឲ្យដល់ពួកញាតិ

២) នាទីដែលត្រូវធ្វើតបស្នងឲ្យដល់អ្នកមានឧបការគុណ

៣) ការដោះនូវបំណុលចាស់ ដែលញាតិវង្សបានធ្វើមកឲ្យខ្លួន

**៣) នាទីរបស់ខ្លួន ដែលត្រូវធ្វើឲ្យសង្គមជាតិ សង្គមលោក** គឺជានាទីចម្បងនិង ចាំបាច់ត្រូវធ្វើក្នុងនាមជាមនុស្សម្នាក់រស់នៅក្នុងសង្គម កុំភ្លេចថា ខ្លួនយើងហ្នឹងមិន ថាធម្មជាតិបានតាក់តែងមក ឲ្យផ្សេងៗ គ្នាដោយការទាប ខ្ពស់ ខ្មៅ ស អាក្រក់ ល្អ យ៉ាងណា ក៏ដោយ ក៏សុទ្ធសឹងតែជាផ្នែកមួយនៃសង្គមដូចៗ គ្នា យើងមានសិទ្ធិ មាន នាទីក្នុងការជួយស្ថាបនាឲ្យសង្គមជាតិ សង្គមលោកចម្រើន លូតលាស់ ទង្វើដែល យើងប្រព្រឹត្តធ្វើក្នុងមួយថ្ងៃៗ សុទ្ធសឹងតែបានផ្តិតកប់ទុក ឲ្យដល់សង្គម ព្រឹត្តកម្ម ទាំងឡាយនោះ អាចក្លាយទៅជាបញ្ហាឲ្យដល់សង្គម ក្នុងផ្នែកអវិជ្ជមានក៏បាន ក្លាយ ទៅជាទស្សនគតិ គំនិតយោបល់ ជាមេបែប ជាដើមក្នុងផ្នែកវិជ្ជមានឲ្យដល់សង្គម ក៏បាន ដូច្នេះ មិនថាអ្នកមាន អ្នកក្រ ស្រទាប់វណ្ណៈខុសគ្នាយ៉ាងណាក៏ដោយ ក៏

ចាំបាច់ត្រូវពឹងអាស្រ័យគ្នាទៅវិញទៅមក ក្នុងផ្នែកណាទីមួយជាមិនខាន ហើយបូកផ្សំរួមគ្នានៃគំនិតយោបល់ នៃរាល់ព្រឹត្តកម្មផ្នែកវិជ្ជមានទាំងឡាយទាំងពួង របស់យើងម្នាក់ៗ ទើបក្លាយបានទៅជាគំនិតរួម ព្រឹត្តកម្មរួម សេចក្តីសុខរួម សង្គមរួមគ្នាយ៉ាងសន្តិសុខ ………។